

# ផ្ទះកក់ក្ដៅ គ្រួសារសុខសាន្ត

វគ្គ៖

# ភាពវៃឆ្លាតក្នុងការចាយ

FIRST FINANCE




Image are Generated with AI


មុនទៅផ្សារ អូន
តែងឆែកមើល ថានៅ
មានអី ហើយខ្វះអី ដែល
គួរទិញថែម




## បញ្ជីមុខទំនិញដែលត្រូវទិញ

| ឈ្មោះទំនិញ | ចំនួន | តម្លៃ១ឯកតា | តម្លៃសរុប |
|---|---|---|---|
| ប្រេងឆា | ១ ដបធំ | ១៥,000 រៀល | ១៥,000 រៀល |
| ប៊ីចេង | ១ ថង់កន្លះគីឡូ | ៥,000 រៀល | ៥,000 រៀល |
| សាប៊ូបោកខោអាវ | ១ ធុង ១០លីត្រ | ៦0,000 រៀល | ៦0,000 រៀល |
| ទឹកលាងចាន | ១ ធុង ៣លីត្រ | ១៥,000 រៀល | ១៥,000 រៀល |
| | | **ទឹកប្រាក់សរុប** | **៩៥,000 រៀល** |


របស់ដែលទុក
បានយូរអូនទិញក្នុង
បរិមាណច្រើន ព្រោះវា
ចំណេញជាង ទិញ
ម្ដងបន្តិចៗ
ឥវ៉ាន់ខ្លះអូនត្រូវ
ឆែកតម្លៃតាមអនឡាញ
២ ទៅ ៣ កន្លែងបន្ថែម
មុនទៅទិញក៏មាន


ម្យ៉ាងទៀតដំណាំ ដែលបងដាំជុំវិញផ្ទះ ក៏ ជួយកាត់បន្ថយចំណាយ យើងគួរសមដែរ! លោកប្តី



## ចាយប្រកបដោយភាពវៃឆ្លាត

- ពិនិត្យមើលរបស់របរដែលមានក្នុងទូរមុនពេលទិញ ជៀសវាងទិញមកបន្ថែម នៅពេលប្រើមិនទាន់អស់
- ធ្វើបញ្ជីមុខទំនិញដែលត្រូវទិញ ដើម្បីដឹងពីទឹកលុយដែលត្រូវប្រើ និងជៀសវាងទិញនូវឥវ៉ាន់ដែលមិនទាន់ត្រូវការប្រើ
- ប្រៀបធៀបតម្លៃក្នុងការទិញនូវបរិមាណច្រើន និងតិច ដើម្បីពិនិត្យថាមួយណាចំណេញជាង
- ប្រៀបធៀបតម្លៃឲ្យបានច្រើនប្រភព សម្រាប់ការទិញទំនិញដែលចំណាយច្រើន

សូមតាមដានភាគបន្ត នៅសប្តាហ៍ក្រោយ

**ផ្ទះកក់ក្ដៅ គ្រួសារសុខសាន្ត** ជាកម្រងរឿងខ្លីៗ ដែលនិយាយពីជីវភាពរស់នៅប្រចាំថ្ងៃរបស់គ្រួសារមួយស្ថិតក្នុងជីវភាពមធ្យម ។ នៅក្នុងវគ្គនីមួយៗនៃរឿងនេះ ត្រូវបានបញ្ចូលសារអប់រំខ្លីៗ ជូន ដល់អ្នកអាន ដើម្បីស្វែងយល់អំពីការគ្រប់គ្រង និងរៀបចំផែនការហិរញ្ញវត្ថុក្នុងគ្រួសារដំណើរការដាក់ស្នើរកម្ចីផលិតផលកម្ចី និងសារអប់រំផ្សេងទៀតទាក់ទងនឹងការប្រើប្រាស់កម្ចីប្រកបដោយប្រសិទ្ធភាព ។

យើងខ្ញុំស្វាគមន៍ទទួលយកគន្លឹះផ្សេងៗទាក់ទងនឹងការគ្រប់គ្រងហិរញ្ញវត្ថុគ្រួសារ តាមការស្នើរសុំពីប្រិយមិត្តដើម្បីបញ្ចូលទៅក្នុងសាច់រឿង ។

ដូច្នេះប្រសិនបើប្រិយមិត្តមាន គន្លឹះដែលល្អៗ អាចផ្ញើរមកកាន់ទំព័រ Facebook របស់
ហ្វឹស ហ្វាយនែន ឬតាមរយអ៊ីម៉ែល
infor@firstfiance.com.kh យើងខ្ញុំនឹងត្រូវពិនិត្យហើយដាក់ជូន ប្រសិនបើយល់ឃើញថា អត្ថបទ ឬគន្លឹះនោះមានប្រយោជន៍ដល់ប្រិយមិត្តអ្នកអានផ្សេងទៀត ។


នាំមកជូនដោយ

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ
ហ្វឹស ហ្វាយនែន ភីអិលស៊ី

FIRST FINANCE

គេហទំព័រ ហ្វឹស ហ្វាយនែន
www.firstfinance.com.kh